នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសដ
**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង
**ថ្ងៃដាក់** : ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jul-2016, 15:57
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សម្ងាត់** អមដោយ **ឧបសម្ពន្ធសម្ងាត់បំផុត** បី និង **ឯកសារភ្ជាប់សម្ងាត់បំផុត** ប្រាំបី

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អជសដ:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

# សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យទទួលយកឯកសារ អនុលោមតាមវិធាន៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**
លោកស្រី ទូច វល័ក្ស
លោក Calvin SAUNDERS

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន៨៧(៣) និង៨៧(៤)[1] និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការដាក់បង្ហាញឯកសារ[2] សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") ស្នើសុំកំណត់ហេតុស្តាប់ចម្លើយ ចំនួន ៣៤ និងរបាយការណ៍នៃសកម្មភាពការស៊ើបអង្កេតចំនួន ១ ពីសំណុំរឿង០០៤ ("សម្ភារៈ") ទទួលយកធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង០០២/០២។ សម្ភារៈទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២នេះ គឺមិនអាចរកបានទេ នៅមុនការចាប់ផ្តើមសវនាការ ហើយនាំទៅរកការបញ្ជាក់ការពិត។ សម្ភារៈទាំងឡាយត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធសម្ងាត់បំផុត ចំនួនបី[3]៖ **ឧបសម្ព័ន្ធ គ(១), ឧបសម្ព័ន្ធ គ(២) និងឧបសម្ព័ន្ធ គ(៣)**។

## II. ការដាក់បង្ហាញពីប្រវត្តិ

2. សហព្រះរាជអាជ្ញា គឺយកចិត្តទុកដាក់ទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥[4] បង្គាប់ឲ្យសហព្រះរាជអាជ្ញាដាក់បង្ហាញជូនទៅអង្គជំនុំជម្រះ និងភាគីនានានូវភស្តុតាងសក្តានុពល ពីសំណុំរឿង០០៣ និង០០៤ នៅលើមូលដ្ឋានជាប់ជាបន្តរហូតដល់ការបញ្ចប់សំណុំរឿង០០២/០២[5]។ សេចក្តីសម្រេចនោះក៏បានបង្គាប់ដល់សហព្រះរាជអាជ្ញាផងដែរថា ឲ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយរបស់បុគ្គលទាំងអស់ នៅក្នុងសំណុំរឿង០០៣ និង

---

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩), ដូចដែលបានពិនិត្យសាឡើងវិញនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង")។

[2] **E363/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ("សេចក្តីសម្រេចលើកាតព្វកិច្ចដាក់បង្ហាញឯកសារ"), ២២ តុលា ២០១៥។ **E319/47/3** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ("សេចក្តីសម្រេចលើសំណើរបស់ សពអ"), ២៩ មិថុនា ២០១៦។

[3] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការជូនដំណឹងអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ២០១២, ទំព័រ១ [ដោយបានបង្គាប់ថា ការដាក់បង្ហាញត្រូវតែបានដាក់ និងបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងដោយចាត់ថ្នាក់បណ្តោះអាសន្នជាប្រភេទឯកសារសម្ងាត់បំផុត ហើយអង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចនៅពេលក្រោយថាតើគួរត្រូវប្តូរចំណាត់ថ្នាក់ឯកសារទាំងនេះឡើងវិញជាឯកសារសម្ងាត់ដែរឬយ៉ាងណា]។

[4] *ដដែលដូចខាងលើ។*

[5] *ដដែលដូចខាងលើ។* កថាខណ្ឌ ២១-២៤, ផ្នែកសម្រេចសេចក្តី, EN 01157631-33, 01157640-41។

០០៤ ដែលត្រូវបានស្នើឲ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២[6]។ អនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល សហព្រះរាជអាជ្ញាក៏មានកាតព្វកិច្ចផងដែរក្នុងការដាក់បង្ហាញឯកសារដែលមានព័ត៌មានពីរប្រភេទជាក់លាក់ដែលបានស្នើសុំដោយ នួន ជា៖ (i) ភស្តុតាងផ្តល់ដោយសាក្សីម្នាក់ដែលធ្លាប់ធ្វើការដោយផ្ទាល់ជាមួយនឹង រស់ ញឹម, ឬ (ii) ភស្តុតាងទាក់ទងនឹងពួកប្រឆាំងនឹង ប៉ុល ពត និង នួន ជា នៅភូមិភាគពាយ័ព្យ នៅមុនថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[7]។ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូង ក្រោយមកបានសម្រេចថាសម្ភារៈនៅក្នុងសំណុំរឿង០០៣ និង០០៤ណាក៏ដោយដែលសហព្រះរាជអាជ្ញាមានបំណងដាក់ដោយអនុលោមតាមវិធាន៨៧(៤) ត្រូវតែដាក់បង្ហាញនៅពេលដែលមានសំណើសុំដាក់បង្ហាញដែលមានសម្អាងហេតុ ដោយអនុលោមតាមវិធាន៨៧(៤)[8]។

3. សហព្រះរាជអាជ្ញាអន្តរជាតិ បានស្វែងរកការអនុញ្ញាតដាក់បង្ហាញសម្ភារៈនៅក្នុង **ឧបសម្ព័ន្ធ ត(១)** ដល់ **ត(៣)** តាមរយៈសំណើមួយដែលបានធ្វើកាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦[9]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (សចសអ) បានចេញសេចក្តីសម្រេចមួយអនុញ្ញាតឲ្យដាក់បង្ហាញនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ ("សេចក្តីសម្រេចរបស់ សចសអ")[10] និងផ្តល់នូវឯកសារដែលបានកោសលុបពាក់ព័ន្ធ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦។ **ឧបសម្ព័ន្ធ ត(១)** ដល់ **ត(៣)** មានឯកសារដែលបានអនុញ្ញាតនៅក្នុងសេចក្តីសម្រេចរបស់ សចសអ ដែលសហព្រះរាជអាជ្ញាចង់ដាក់ អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង និងបញ្ជាក់ពីប្រភេទនៃការដាក់បង្ហាញបន្ថែមណាមួយដែលអាចអនុវត្តបានទៅនឹងឯកសារនីមួយៗ។ ឯកសារនានាដែលបានអនុញ្ញាតនៅក្នុងសេចក្តីសម្រេចរបស់ សចសអ ដែលចូលទៅក្នុងប្រភេទនៃការដាក់បង្ហាញ, ប៉ុន្តែមិនត្រូវបានស្វែង

---

6 *ដដែលដូចខាងលើ*។ កថាខណ្ឌ ២៥-២៧, ផ្នែកសម្រេចសេចក្តី, EN 01157634-35, 01157640-41។

7 **F2/4/2** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១, ១៦ មីនា ២០១៥, កថាខណ្ឌ២៤។

8 **E319/47/3** សេចក្តីសម្រេចលើសំណើរបស់ សពអ, ២៩ មិថុនា ២០១៦, កថាខណ្ឌ២២។

9 សំណុំរឿង០០៤-**D193/75** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ ចូលទៅក្នុងសំណុំរឿង០០២, ១២ ឧសភា ២០១៦។

10 សំណុំរឿង០០៤-**D193/90** សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ ចូលទៅក្នុងសំណុំរឿង០០២ (D193/70, D193/72, និង D193/84) "សេចក្តីសម្រេចរបស់ សចសអ", ១៥ កក្កដា ២០១៦។

រកឲ្យទទួលយក ដោយអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង, ត្រូវបានដាក់បង្ហាញនៅក្នុងការដាក់ជូនដោយឡែកមួយ[11]។

## III. លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយក

4. សម្ភារៈឆ្លើយតបតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយក ដែលបានចែងនៅក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង ដោយសារវាមានលក្ខណៈយថាភូត ជឿជាក់បាន និងពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកម្មវត្ថុនៃសំណុំរឿង០០២/០២[12] ដូចដែលត្រូវបានរៀបរាប់យ៉ាងពិស្តារនៅក្នុង**ឧបសម្ព័ន្ធ ត(១)** ដល់ **ត(៣)**។ ឯកសារទាំងនោះមានសក្ខីកម្មតាមប្រធានបទដូចតទៅនេះ៖

ក. អំពើប្រល័យពូជសាសន៍លើជនជាតិចាម[13] រួមមាន សក្ខីកម្មយ៉ាងពិស្តាររបស់សាក្សីដែលឃើញផ្ទាល់អំពីការសម្លាប់រង្គាលនៃជនជាតិចាម[14] និងភស្តុតាងនៃការធ្លាក់ចុះយ៉ាងគំហុកនៃប្រជាជនចាមនៅក្នុងភូមិនានានៃស្រុកកំពង់សៀម[15]។

ខ. អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម[16] រួមមាន កំណត់ហេតុស្តាប់ចម្លើយពីអតីតកម្មាភិបាលម្នាក់ ដែលបានចូលរួមនៅក្នុងការសម្លាប់រង្គាលនៃជនជាតិខ្មែរក្រោម[17] កំណត់ហេតុស្តាប់ចម្លើយពីសាក្សីពីរនាក់ ពាក់ព័ន្ធនឹងការសម្លាប់រង្គាលមួយនៃការសម្លាប់

[11] **F2/4/2/5** ការសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពីសំណុំរឿង០០៤ ពាក់ព័ន្ធនឹងសំណុំរឿង០០២, ២២ កក្កដា ២០១៦ (នឹងត្រូវបានជូនដំណឹង)។

[12] **E390/2** សេចក្តីសម្រេចលើសំណើលើកទី១ របស់ នួន ជា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង សុំកោះហៅសាក្សីបន្ថែមមួយរូប និងទទួលយកកិច្ចសម្ភាសន៍មួយសម្រាប់វគ្គសវនាការស្តីពីមន្ទីរសន្តិសុខភ្នំក្រោលនៃសំណុំរឿង០០២/០២, ៤ ឧសភា ២០១៦, កថាខណ្ឌ៣ ["អង្គជំនុំជម្រះរម្លឹកថា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ក្នុងកំឡុងពេលសវនាការ អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភស្តុតាងនោះក៏ស្របទៅនឹងបទដ្ឋាននៃភាពពាក់ព័ន្ធ ភាពជឿជាក់បាន និងយថាភាពតាមការវិភាគបឋម អនុលោមតាមវិធាន៨៧(៣)។ អង្គជំនុំជម្រះធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣)"]។

[13] #១-៩ នៃ**ឧបសម្ព័ន្ធ ត(១)**។

[14] *សូមអាន ឧទា.* #១, #៣, #៥ នៅក្នុង**ឧបសម្ព័ន្ធ ត(១)**។

[15] *សូមអាន ឧទា.* #៤, #៦ នៅក្នុង**ឧបសម្ព័ន្ធ ត(១)**។

[16] #១០-១៦ នៅក្នុង**ឧបសម្ព័ន្ធ ត(១)**, #១-៣ នៅក្នុង**ឧបសម្ព័ន្ធ ត(២)**។

[17] #១-២ នៅក្នុង**ឧបសម្ព័ន្ធ ត(២)**។

វង្គាលដដែល[18] និងរឿងរ៉ាវមួយរបស់លេខាស្រុកម្នាក់ដែលបានថ្លែងថា ខ្មែរក្រោម គឺជា "យួន" ហើយថ្នាក់លើបានសម្រេចថាត្រូវតែ "បោសសម្អាត" ពួកគេ[19]។

គ. ក្រុមគោលដៅអតីតទាហានសាធារណៈរដ្ឋខ្មែរ[20] រួមមាន កំណត់ហេតុស្តាប់ចម្លើយមួយពីអតីតកម្មាភិបាលម្នាក់ ដែលបានចូលរួមនៅក្នុងការសម្លាប់វង្គាលនៃពួកអតីតទាហានចំនួន ៥០នាក់ នៅក្នុងខេត្តបាត់ដំបង[21] និងម្នាក់ផ្សេងទៀតដែលបានជូនដំណើរអតីតទាហានសាធារណៈរដ្ឋខ្មែរ និងមន្ត្រីស៊ីវិលចូលទៅក្នុងព្រៃនៅស្រុកបាកាន ហើយឈរយាមនៅពេលដែលបំពង់ករបស់ពួកគេត្រូវបានកាត់[22]។

ឃ. ការបោសសម្អាត[23] រួមបញ្ចូលពីសាក្សីដែលរៀបរាប់អំពីការចូលរួមការប្រជុំមួយ ដែល នួន ជា បាននិយាយថា ពួកក្បត់នៅក្នុងភូមិភាគពាយ័ព្យស្ថិតនៅក្នុងចំណោមប្រជាជន ១៧ មេសា និងថាភូមិភាគនិរតីត្រូវបានបញ្ជូនឲ្យទៅគ្រប់គ្រង[24]។

ង. គុកក្រាំងតាចាន់ រួមមានចម្លើយរបស់ ហ៊ុន គឹមសេង ដែលជាម្តាយរបស់សាក្សី មាស សុខា អំពីបទពិសោធន៍របស់គាត់នៅគុកក្រាំងតាចាន់[25]។

ច. អាពាហ៍ពិពាហ៍ដោយបង្ខំ[26] ដោយរួមទាំងចម្លើយពីអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ ដែលបានរៀបរាប់អំពី អោ អាន ដែលជាអនុលេខាភូមិភាគកណ្តាល បានយោងទៅលើផែនការរបស់ ប៉ុល ពត ដើម្បីបង្កើនចំនួនប្រជាជន និងបានថ្លែងថាគូស្រករត្រូវតែបង្កើតកូនក្រោយ

---

[18] #១០ នៅក្នុង**ឧបសម្ព័ន្ធ ត(១)**, #៣ នៅក្នុង**ឧបសម្ព័ន្ធ ត(២)**។

[19] #១០ នៅក្នុង**ឧបសម្ព័ន្ធ ត(១)**។

[20] #១៧-១៨ នៅក្នុង**ឧបសម្ព័ន្ធ ត(១)**, #៣ នៅក្នុង**ឧបសម្ព័ន្ធ ត(២)**។

[21] #១៧ នៅក្នុង**ឧបសម្ព័ន្ធ ត(១)**។

[22] #៣ នៅក្នុង**ឧបសម្ព័ន្ធ ត(២)**។

[23] #១៩-២២ ក្នុងឧបសម្ព័ន្ធ ត(១), #១-២ ក្នុងឧបសម្ព័ន្ធ ត(៣)។

[24] #១៩ ក្នុងឧបសម្ព័ន្ធ ត(១)។

[25] #២៣ ក្នុងឧបសម្ព័ន្ធ ត(១)។

[26] #២៤-២៨ ក្នុងឧបសម្ព័ន្ធ ត(១)។

ពេលរៀបពាហ៍ពិពាហ៍ ដើម្បី "បង្កើតកម្លាំងថ្មី"[27] និងការរៀបរាប់រឿងដែលស្ត្រីបានធ្វើអត្តឃាតដោយសារតែត្រូវបានគេបង្ខំឲ្យរៀបការ[28]។ និង

ឆ. ខ្សែចង្វាក់នៃការទំនាក់ទំនង ដោយរួមមាន ចម្លើយរបស់អង្គរក្សរបស់ អោ អាន[29] ប្រធានអង្គភាពបកប្រែលេខសម្ងាត់ និងទូរលេខ ក-១៨ នៅភ្នំពេញ[30] និង និវេសរបស់ វន សាន ដែលជាប្រធានយោធាភូមិភាគពាយ័ព្យ[31]។

**ឧបសម្ព័ន្ធ គ(១) ដល់ (៣)** កំណត់ពីរបៀបដែលព័ត៌មានមាននៅក្នុងចម្លើយនីមួយៗពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២ និងការយោងទៅលើផ្នែកជាក់លាក់នៃដីកាដំណោះស្រាយ ដែលឯកសារនីមួយៗពាក់ព័ន្ធ។

5. វិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ចែងថា ភាគីដែលស្នើសុំឲ្យទទួលយកភស្តុតាងថ្មីត្រូវបំពេញលក្ខខណ្ឌតម្រូវរបស់អង្គជំនុំជម្រះថាភស្តុតាងស្នើសុំនោះមិនអាចរកបាន មុនពេលបើកការជំនុំជម្រះ ហើយអង្គជំនុំជម្រះបានថ្លែងថា ឯកសារថ្មីពីសំណុំរឿង០០៣ និង០០៤ មិនត្រូវបានចាត់ទុកថា 'អាចរកបាន"រហូតដល់ពេលឯកសារទាំងនោះត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញដោយ កសចស[32]។ សម្ភារៈទាំងនោះត្រូវបានផលិតនៅក្នុងសំណុំរឿង០០៤ ក្រោយពេលដែលការជុំជំនុំជម្រះបានចាប់ផ្តើមក្នុងខែមិថុនា ឆ្នាំ២០១១[33] និងមិនត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញទៅក្នុងសំណុំរឿង០០២ ដោយសហចៅក្រមអន្តរជាតិទេ រហូតដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦[34]។ ហេតុដូច្នេះ ឯកសារដែលត្រូវបានស្នើសុំទាំងនោះ មិនអាចរកបានទេនៅមុនពេលបើកសវនាការជំនុំជម្រះ។

---

27 #២៧ ក្នុងឧបសម្ព័ន្ធ គ(១)។

28 #២៤, #២៦ ក្នុងឧបសម្ព័ន្ធ គ(១)។

29 #១-២ ក្នុងឧបសម្ព័ន្ធ គ(៣)។

30 #២៩ ក្នុងឧបសម្ព័ន្ធ គ(១)។

31 #៣០ ក្នុងឧបសម្ព័ន្ធ គ(១)។

32 **E363/3** ដីកាសម្រេចស្តីពីកាតព្វកិច្ចដាក់បង្ហាញ, ២២ តុលា ២០១៥, ជើងទំព័រ៦៤។

33 **E307/1** សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3), ១១ មិថុនា ២០១៤។ **E307/1/2** សេចក្តីសម្រេចលើសំណើសុំរួមឲ្យសម្រេចសាជាថ្មីលើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង, ២១ តុលា ២០១៤, កថាខណ្ឌ១០។

34 សំណុំរឿង០០៤-**D193/90** ដីកាសម្រេច សចសអ, ១៥ កក្កដា ២០១៦។

**6.** វិធាន ៨៧(៤) តម្រូវបន្ថែមទៀតថា ភ័ស្តុតាងថ្មីត្រូវតែជឿជាក់ថាមានប្រយោជន៍ដល់ការស្វែងរកការពិត។ សហព្រះរាជអាជ្ញាសាទរដែលថា អង្គជំនុំជម្រះសាលាដំបូងកំពុងតែអនុវត្តការពិនិត្យពិច័យខ្លាំងជាងមុនចំពោះភ័ស្តុតាងថ្មី[35] ប៉ុន្តែ សហព្រះរាជអាជ្ញាយល់ឃើញថា ការទទួលយកឯកសារទាំងអស់នេះ មានសារៈសំខាន់ណាស់ ដោយយោងទៅលើសេចក្តីអធិប្បាយអង្គហេតុលម្អិត និងច្រើន ដែលទាក់ទងទៅនឹងការចោទប្រកាន់ធ្ងន់ធ្ងរបំផុត នៅក្នុងការជំនុំជម្រះ និងលក្ខណៈពិសេសនៃភ័ស្តុតាងដែលបានរៀបរាប់នៅក្នុង**ឧបសម្ព័ន្ធ ក(១) ដល់ ក(៣)**។

## IV. **លក្ខខណ្ឌនៃការដាក់បង្ហាញ**

7. ការអនុញ្ញាតឱ្យដាក់បង្ហាញសម្ភារៈក្នុង **ឧបសម្ព័ន្ធ ក(១)** គឺត្រូវគោរពតាមលក្ខខណ្ឌតម្រូវនានាដែលបានដាក់ដោយ កសចស ដូចខាងក្រោម[36]៖

ក. រាល់សម្ភារៈទាំងអស់ដែលបានផ្តល់ពីសំណុំរឿង០០៤ ត្រូវចាត់ទុកជាសម្ងាត់។

ខ. ក្នុងករណីដែលសម្ភារៈត្រូវបានទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង០០២ សម្ភារៈទាំងនោះ ត្រូវចាត់ទុកជាការសម្ងាត់។

គ. ក្នុងករណីដែលសាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី ដែលឯកសាររបស់គាត់ត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញ ត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម ពួកគាត់អាចធ្វើដូច្នេះបាននៅក្នុងវគ្គសវនាការសាធារណៈរបស់តុលាការ ដរាបណាឈ្មោះ និងអត្តសញ្ញាណរបស់ពួកគាត់ត្រូវបានរក្សាជាការសម្ងាត់ លើកលែងតែ ស៊ុំ ចាន់ថុល និង ហ៊ុន គឹមសេង។

ឃ. សម្ភារៈទាំងឡាយ មិនត្រូវផ្សព្វផ្សាយឱ្យលើសពីបុគ្គលទាំងឡាយណា ដែលត្រូវបានកំណត់អត្តសញ្ញាណយ៉ាងជាក់ច្បាស់នៅក្នុងនោះឡើយ។

ង. សម្ភារៈទាំងឡាយមិនត្រូវផ្សព្វផ្សាយទៅកាន់សាធារណៈជនក្នុងទម្រង់ណាមួយ ឬតាមរយៈមធ្យោបាយសារព័ត៌មានបែបណាក៏ដោយ ដែលលើសពីភស្តុតាងដែលបានបង្ហាញក្នុងសវនាការបើកចំហររបស់តុលាការឡើយ។

---

35 **E319/47/3** សេចក្តីសម្រេចលើសំណើរបស់ សពអ, ២៩ មិថុនា ២០១៦, កថាខណ្ឌ២៣។

36 សំណុំរឿង០០៤-**D193/90** សេចក្តីសម្រេចរបស់ សចសអ, ១៥ កក្កដា ២០១៦, កថាខណ្ឌ១៦។

ច. ភាគី មេធាវីការពារក្តី ឬបុគ្គលដទៃទៀតណាក៏ដោយ ដែលបានអាន លើកឡើង ឬបើមិនដូច្នោះទេ បានប្រើប្រាស់ឯកសារណាមួយដែលបានដាក់បង្ហាញ ត្រូវកំណត់អត្តសញ្ញាណសាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី តែដោយរហស្សនាមដែលបានដាក់ឱ្យសម្រាប់សំណុំរឿង ០០២ប៉ុណ្ណោះ និងប្រើការរៀបរាប់ដែលបានលៃលកយ៉ាងសមហេតុផល ដើម្បីចៀសវាងការកំណត់អត្តសញ្ញាណសាក្សីដោយព័ត៌មានដទៃទៀត លើកលែងតែ ស៊ុំ ចាន់ថុល និង ហ៊ុន គឹមសេង។

ឆ. ឯកសារដែលបានដាក់បង្ហាញ ត្រូវផ្តល់ជូនទៅមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងពីររូប មេធាវីប្រចាំការរបស់ ខៀវ សំផន (“មេធាវីប្រចាំការ”) និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសំណៅថតចម្លងអេឡិកត្រូនិច។

ជ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់បង្ហាញសម្ភារៈដែលបានផ្តល់ឱ្យនេះ ដោយអនុលោមតាមសេចក្តីសម្រេចនេះ ឱ្យទៅតែសមាជិកនៃក្រុមការងាររបស់ពួកគាត់ដែលទទួលបានការងារជាផ្លូវការ តាមវិធាន២២(៥) និងវិធាន១២(៤)*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ជាមួយនឹងកម្មសិក្សាការីរបស់ពួកគាត់ដែលត្រូវបានចាត់តាំងជាផ្លូវការប៉ុណ្ណោះ។

ឈ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ចម្លងនូវសំណៅថតចម្លងនៃឯកសារដើមដែលពួកគេបានទទួលឡើយ ក្រៅពីសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងនៃសម្ភារៈនោះ ដោយសមាជិកនៃក្រុមនានារបស់ខ្លួនដែលត្រូវបានណែនាំ ឬត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់នោះប៉ុណ្ណោះ។

ញ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវរក្សាកំណត់ហេតុស្តីពីសំណៅដែលខ្លួនបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ចម្លងនូវសំណៅថតចម្លងសម្រាប់ប្រើប្រាស់ផ្ទៃក្នុង ក្នុងរបៀបមួយដែលអាចត្រួតពិនិត្យឡើងវិញបាន។

ដ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីសំណៅគ្មានការអនុញ្ញាតណាមួយនៃសម្ភារៈដែលបានដាក់បង្ហាញ

សមាជិករូបនោះ ត្រូវចាត់គ្រប់វិធានការទាំងអស់ជាបន្ទាន់ ដើម្បីរក្សាការពារសុវត្ថិភាព និងប្រគល់សំណៅសម្ភារៈឯកសារនោះជូន សចអ វិញ។ និង

ឋ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កម្រិតទាំងនេះ សមាជិករូបនោះត្រូវរាយការណ៍ជាបន្ទាន់អំពីការរំលោភបំពាននោះជូន សចអ។

8. សម្ភារៈក្នុង **ឧបសម្ព័ន្ធ ត(២)** ត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញស្របតាមការដាក់កម្រិត និងរបៀបរបបដែលបានដាក់ដោយ សចសអ ប៉ុន្តែបានប្រែប្រួលទៅតាមវិធានការដែលមានកម្រិតតឹងរឹងជាងដូចខាងក្រោម ដោយសារតែលក្ខណៈរសើប និងការសម្ងាត់នៃកិច្ចស៊ើបសួរដែលកំពុងធ្វើក្នុងសំណុំរឿង០០៤ ទន្ទឹមនឹងសំណើសុំវិធានការការពារដោយសាមីសាក្សីមួយចំនួន[37]៖

គ. ក្នុងករណីសាក្សីដែលសម្ភារៈរបស់គាត់ មានចុះក្នុងបញ្ជីនៃ **ឧបសម្ព័ន្ធ ត(២)** ត្រូវបានកោះហៅឱ្យមានបំភ្លឺ នោះអង្គជំនុំជម្រះគួរជូនដំណឹងដល់ កសចស និងអង្គភាព WESU អំពីសេចក្តីសម្រេចដូច្នេះនៅក្នុងពេលវេលាមួយគ្រប់គ្រាន់ ដើម្បីឱ្យ WESU អាចវាយតម្លៃពីវិធានការការពារសមស្របដែលត្រូវការ ដើម្បីដោះស្រាយអំពីកង្វល់ផ្នែកសុវត្ថិភាព និងសន្តិសុខរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

ង. គ្មានសម្ភារៈណាមួយនៅក្នុង **ឧបសម្ពន្ធ ត(២)** ត្រូវបានផ្សព្វផ្សាយទៅកាន់សាធារណជនក្នុងទម្រង់ណាមួយ ឬតាមរយៈទម្រង់សារព័ត៌មានណាមួយក៏ដោយ ឬត្រូវបានបង្ហាញ ឬយោង នៅក្នុងសវនាការបើកចំហរក្នុងលក្ខណៈបែបណាមួយឡើយ។

ច. ភាគីណាក៏ដោយ ក្រុមមេធាវីការពារក្តី ឬបុគ្គលដទៃទៀត ដែលត្រូវអាន លើកយោង ឬបើមិនដូច្នោះទេ ប្រើប្រាស់ឯកសារណាមួយក្នុងចំណោមឯកសារនានា ដែលបានដាក់បង្ហាញនៅក្នុង **ឧបសម្ព័ន្ធ ត(២)** ត្រូវស្នើសុំសវនាការអសាធារណៈ មុនពេលធ្វើដូច្នោះ ហើយក្នុងករណីណាក៏ដោយ ត្រូវកំណត់អត្តសញ្ញាណអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតែតាមរយៈរហស្សនាមដែលបានដាក់ឱ្យ សម្រាប់សំណុំរឿង០០២ និងត្រូវប្រើប្រាស់តែសេចក្តីរៀបរាប់ផ្សេងៗ ដែលបានគណនាសមហេតុសមផលប៉ុណ្ណោះ

[37] សំណុំរឿង០០៤-**D193/90** សេចក្តីសម្រេចរបស់ សចសអ, ១៥ កក្កដា ២០១៦, កថាខណ្ឌ១៧។

ដើម្បីចៀសវាងនូវការកំណត់អត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនោះ តាមរយៈព័ត៌មានដទៃទៀត។

9. សម្ភារៈនៅក្នុង **ឧបសម្ព័ន្ធ ត(៣)** ត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញស្របតាមការដាក់កម្រិត និងរបៀបរបបដែលបានដាក់ដោយ សចសអ ដូចបានគូសបញ្ជាក់ក្នុងកថាខណ្ឌ៧ ប៉ុន្តែបានប្រែប្រួលទៅតាមវិធានការដែលមានកម្រិតតឹងរឹងជាងដូចខាងក្រោម[38]៖

ក. ក្នុងករណីសាក្សីដែលសម្ភារៈរបស់គាត់មានចុះក្នុងបញ្ជីនៃ **ឧបសម្ព័ន្ធ ត(៣)** ត្រូវបានកោះហៅឲ្យមកបំភ្លឺ នោះពួកគេត្រូវធ្វើក្នុងសវនាការអសាធារណៈ[39]។

ង. គ្មានសម្ភារៈណាមួយដែលបានផ្តល់ក្នុង **ឧបសម្ពន្ធ ត(៣)** ត្រូវបានផ្សព្វផ្សាយទៅកាន់សាធារណជន ក្នុងទម្រង់ណាមួយ ឬតាមរយៈទម្រង់សារព័ត៌មានណាមួយក៏ដោយ ឬត្រូវបានបង្ហាញ ឬយោង នៅក្នុងសវនាការបើកចំហរក្នុងលក្ខណៈបែបណាមួយឡើយ។

ច. ភាគីណាក៏ដោយ ក្រុមមេធាវីការពារក្តី ឬបុគ្គលដទៃទៀត ដែលត្រូវអាន លើកយោង ឬបើមិនដូច្នោះទេ ប្រើប្រាស់ឯកសារណាមួយក្នុងចំណោមឯកសារនានា ដែលបានដាក់បង្ហាញនៅក្នុង **ឧបសម្ព័ន្ធ ត(៣)** ត្រូវស្នើសុំសវនាការអសាធារណៈ មុនពេលធ្វើដូច្នោះ ហើយក្នុងករណីណាក៏ដោយ ត្រូវកំណត់អត្តសញ្ញាណសាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែតាមរយៈរហស្សនាមដែលបានដាក់ឲ្យ សម្រាប់សំណុំរឿង ០០២ និងត្រូវប្រើប្រាស់តែសេចក្តីរៀបរាប់ផ្សេងៗ ដែលបានគណនាសមហេតុសមផលប៉ុណ្ណោះ ដើម្បីចៀសវាងនូវការកំណត់អត្តសញ្ញាណសាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនោះ តាមរយៈព័ត៌មានដទៃទៀត។

10. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបំភ្លឺបន្ថែមថា៖

"សម្រាប់គោលបំណងនៃសេចក្តីសម្រេចរបស់គាត់ ពាក្យថា "សាធារណៈ" មានន័យនិងរួមបញ្ចូលនូវគ្រប់មនុស្ស រដ្ឋាភិបាល អង្គការ ស្ថាប័ន ក្រុមហ៊ុន សមាគម និងក្រុម

[38] សំណុំរឿង០០៤-**D193/90** សេចក្តីសម្រេចរបស់ សចសអ, ១៥ កក្កដា ២០១៦, កថាខណ្ឌ១៨។

[39] សហព្រះរាជអាជ្ញាសូមរក្សាសិទ្ធិដើម្បីជំទាស់ទៅនឹងការដាក់ឲ្យមានវគ្គសវនាការអសាធារណៈ ប្រសិនបើសាក្សីរូបនេះត្រូវបានកោះឲ្យមកបំភ្លឺ។

ទាំងអស់ ក្រៅពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង បុគ្គលិកផ្នែកគ្រប់គ្រងតុលាការ សហព្រះរាជអាជ្ញា និងតំណាងរបស់ខ្លួន ជនជាប់ចោទ និងបុគ្គលិកដូចបានកំណត់ជាផ្លូវការក្នុងវិធាន២២(៥) និងវិធាន១២(៤)*ស្ទួនពីរ* ដែលបានអនុញ្ញាតដោយក្រុមមេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចចូលពិនិត្យមើលសម្ភារៈសម្ងាត់នោះបាន។ ពាក្យថា "សាធារណៈ" ក៏រាប់បញ្ចូលផងដែរ ដោយគ្មានកម្រិតនូវសមាជិកគ្រួសារ មិត្តភក្តិរបស់ជនជាប់ចោទ និងអ្នកដែលជនជាប់ចោទធ្លាប់សេពគប់ ជនសង្ស័យ មេធាវីការពារក្តី និងសមាជិកនៃបុគ្គលិករបស់ពួកគាត់រៀងៗខ្លួននៅក្នុងសំណុំរឿង ឬដំណើរការនីតិវិធីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មាន"។

## V. ដំណោះស្រាយដែលស្នើឡើង

11. អាស្រ័យដូចមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើ ដោយអនុលោមតាមវិធាន៨៧(៣) និង(៤) ឲ្យអង្គជំនុំជម្រះសាលាដំបូងដាក់ទៅក្នុងសំណុំរឿង០០២/០២ និងទទួលយកជាភ័ស្តុតាងនូវឯកសារដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធ គ(១), ឧបសម្ព័ន្ធ គ(២)** និង **ឧបសម្ព័ន្ធ គ(៣)**៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |